# ព្រះរាជក្រម

នស/រកម/០៤០៦/០០៨

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមការកំណត់របស់មាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# វិសោធនកម្ម
# ច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ
# ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

**មាត្រា មួយ.-**

មាត្រា ១ និងមាត្រា ២ នៃច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម :

**មាត្រា ១ .- ថ្មី**

យោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ត្រូវដាក់ឱ្យចូលនិវត្តន៍អាស្រ័យតាមលក្ខខណ្ឌដូចខាងក្រោម :

១-នាយទាហានចាប់ពីថ្នាក់វរសេនីយ៍ឯក និងវរនាវីឯកឡើងទៅ នៅពេលដល់អាយុ ៦០ (ហុកសិប) ឆ្នាំ

២-នាយទាហានថ្នាក់វរសេនីយ៍ទោ និងវរនាវីទោ នៅពេលដល់អាយុ ៥៨ (ហាសិបប្រាំបី) ឆ្នាំ

៣-នាយទាហានចាប់ពីថ្នាក់នាយចំណង់ និងនាយនាវីចំណង់ ដល់ថ្នាក់វរសេនីយ៍ត្រី និងវរនាវីត្រី នៅពេលដល់អាយុពី ៤៣ (សែសិបបី) ឆ្នាំ ទៅ ៥៥ (ហាសិបប្រាំ) ឆ្នាំ ។

៤-នាយទាហានរងចាប់ពីថ្នាក់ពលបាលត្រី និងចក្របាលត្រី ដល់ថ្នាក់ព្រិន្ទបាលឯក និងនាយចក្របាលឯក នៅពេលដល់អាយុពី ៣៨ (សាមសិបប្រាំបី) ឆ្នាំ ទៅ ៤២ (សែសិបពីរ) ឆ្នាំ ។

នាយទាហានថ្នាក់ឧត្តមសេនីយ៍ ឧត្តមនាវីវរជន និងវរសេនីយ៍ឯក កងទ័ពជើងអាកាស វរនាវីឯកកងទ័ពជើងទឹក ដែលមានគុណសម្បត្តិនិងសមត្ថភាព ឬជាអ្នកជំនាញឯកទេស ទោះបីដល់អាយុចូលនិវត្តន៍ក៏ដោយ តាមការស្នើសុំរបស់សាមីខ្លួន ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬតាមតម្រូវការចាំបាច់របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចត្រូវរក្សាទុកដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ប្រទេសជាតិ ។

យោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ អាចស្នើសុំចូលនិវត្តន៍មុនពេលកំណត់បាន ។

លក្ខខណ្ឌ និងបែបបទនៃការចូលនិវត្តន៍តាមការកំណត់និងការចូលនិវត្តន៍មុនពេលកំណត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ២ .- ថ្មី

យោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទអាចទទួលរបបសោធននិវត្តន៍បាន ត្រូវមានលក្ខខណ្ឌដូចខាងក្រោម :

ក-របបសោធននិវត្តន៍អប្បបរមា

១-ចំពោះយោធិនអាជីព ដែលបានបំពីការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពយ៉ាងតិច ១០ (ដប់) ឆ្នាំ ចំពោះបុរស និងយ៉ាងតិច ៨ (ប្រាំបី) ឆ្នាំ ចំពោះនារី ។

២-ចំពោះយោធិនអាជីពដែលបានបំពីការងារមិនប៉ះពាល់ដល់សុខភាព ឬ គ្រោះថ្នាក់ផ្សេងៗចំនួន ២០ (ម្ភៃ) ឆ្នាំ ចំពោះបុរស និងចំនួន ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះនារី ។

ខ-របបសោធននិវត្តន៍អតិបរមា

១-ចំពោះយោធិនអាជីព ដែលបានបំពីការងារនៅតំបន់លំបាក ការ

ការគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពយ៉ាងតិច ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបុរស និង យ៉ាងតិច ១២ (ដប់ពីរ) ឆ្នាំ ចំពោះនារី ។

២-ចំពោះយោធិនអាជីពដែលបានបំពេញការងារមិនប៉ះពាល់ដល់សុខភាព ឬគ្រោះថ្នាក់ផ្សេងៗលើសពី ២០ (ម្ភៃ) ឆ្នាំ ចំពោះបុរស និងលើសពី ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះនារី ។

៣-ចំពោះឧត្តមសេនីយ៍ ឧត្តមនាវី ឬវីរជនក្នុងកងយោធពលខេមរភូមិន្ទដែលបានបំពេញលក្ខខណ្ឌដូចមានចែងនៅចំណុច (គ) ខាងលើ ត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមា ។

៤-ចំពោះយោធិនពិការ ដែលនៅបំពេញការងារជាប់រហូតដល់អាយុចូលនិវត្តន៍ ។

ដោយឡែក លក្ខខណ្ឌ របៀបបទស្តីពីរបបឧបត្ថម្ភចំពោះយោធិនពិការដែលបំពេញការងារមិនបាន យោធិនពលី មរណៈ បង្កស្លាប់ និងបាត់ខ្លួនត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ពីរ.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៦

ពរល.០៦០៤.១៣៤ ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

ហត្ថលេខា

ទៀ បាញ់

លេខ ១៦១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

សោខី តាន់